ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

តុលាការព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧២ អ.ក

ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣

សំណុំរឿងស៊ើបសួរលេខ ២២៤ ស.ស

ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣

សំណុំរឿងជំនុំជម្រះលេខ ៧៥២ ជ.រ

ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣

សាលក្រមព្រហ្មទណ្ឌលេខ ១០៩ ឋ

ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

កាលបរិច្ឆេទនៃសវនាការ ៖ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣។

សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ០៩ ព្រឹក។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។

សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ១០ ព្រឹក។

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

### ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

ឈ្មោះ [redacted] **សុខណា** ហៅ នុយ ភេទប្រុស កើតថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៩ (អាយុ ២៤ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ជាំខ្ទឹម។

ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្តាល។

ទីលំនៅភូមិ[redacted] ខេត្តកណ្តាល។។

ឪពុកឈ្មោះ[redacted]ម៉េង (ស) ម្តាយឈ្មោះ[redacted]ធា (រ) នៅលីវ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ **គ្មាន**។ (ក្នុងឃុំ)

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣។



Scanned with CamScanner

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣។

ត្រូវជាប់ចោទពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិព្រៃកតាឡៃ ឃុំព្រៃកអំពិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យប្រតិភូគណៈមេធាវីប្រចាំខេត្តកណ្ដាល។

លោកស្រី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យអគារលេខ២២៤D ផ្លូវលេខ២០ ភូមិព្រៃកតាឡុង១ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**ខ. អំពីអត្តសញ្ញាណដើមបណ្ដឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] **ធន** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុន។

ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពត។

ទីលំនៅភូមិ[redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted]ជី (រ) ម្ដាយឈ្មោះ[redacted] **ង៉ោ** (រ) ប្រពន្ធឈ្មោះ[redacted] **សូលី** គ្មានកូន។

**សំណុំរឿងព្រហ្មទណ្ឌនេះបញ្ជូនមកជំនុំជម្រះតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២១១ ដកជស (ន)/២៣ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ដែលមាន៖**

**អង្គហេតុដែលប្ដឹងមកតុលាការ**

កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ៧ និង ៣០ នាទី មានករណី លួចមានស្ថានទម្ងន់ទោស (គាស់ផ្ទះ) ស្ថិតនៅក្នុងភូមិព្រៃកតាឡៃ ឃុំព្រៃកអំបិល ស្រុកស្អាង ខេត្តកណ្ដាល បង្កឡើងដោយឈ្មោះ [redacted] **សុខណា** ហៅ **នុយ** ភេទប្រុស អាយុ ២៤ ឆ្នាំ បានយកដែកគាស់ទៅគាស់របងលួសសំណាញ់ និងចម្រឹងបង្អួចផ្ទះជនរងគ្រោះឈ្មោះ [redacted] **ធន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ហើយបានរើរបស់របរក្នុងផ្ទះ និងបានវ៉ៃបំបែកកូនជ្រូកដីដែលមានទាំងលុយខ្មែរ និងលុយដុល្លារសរុបចំនួន **១.០០០.០០០ (មួយលាន) រៀល** យកទៅចាយវាយបាត់អស់។ បន្ទាប់ពីជនរងគ្រោះត្រឡប់មកពីខេត្តតាកែវវិញក៏ឃើញរបស់របរក្នុងផ្ទះរប៉ាត់រប៉ាយ និងកូនជ្រូកត្រូវបានគេបោកយកលុយបាត់អស់ រួចក៏បានទៅដាក់ពាក្យបណ្ដឹងតែម្ដង។ លុះដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ទើបសមត្ថកិច្ចប៉ុស្ដិ៍ព្រៃកអំបិលឃាត់ខ្លួនឈ្មោះ [redacted] សុខណា ហៅ [redacted] បាន។

**អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្ដី**

**ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្ដី**

អំពីវិវាទកម្មស្ដីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

១. ការសួរចម្លើយជនជាប់ចោទ

**១.១.** ឈ្មោះ [redacted] សុខណា ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ ខ្លួនមិនចេះប្រើប្រាស់គ្រឿងញៀន និងចែកចាយគ្រឿងញៀនទេ។ មូលហេតុដែលសមត្ថកិច្ចនគរបាលប៉ុស្តិ៍ព្រែកអំបិលនាំខ្លួនមកកាន់ទីនេះដោយសាររូបខ្លួនបានធ្វើសកម្មភាពចូលគាស់ផ្ទះឈ្មោះ ធន បានប្រាក់ចំនួន ១.០០០.០០០ (មួយលានរៀល)។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០៧ ព្រឹក ខ្លួនបាននៅឈរខាងមុខផ្ទះរបស់តែម្នាក់ឯងដែលមានចម្ងាយប្រហែល ៥០ ម៉ែត្រពីផ្ទះឈ្មោះ ធន នៅខាងត្បូងផ្ទះរបស់ខ្លួន ដោយចាំមើលឈ្មោះ ធន បើកឡានចេញពីផ្ទះទៅជាមួយបងប្អូននឹងក្រុមគ្រួសាររបស់គាត់។ លុះដល់វេលាម៉ោង ០៧ និង ៣០ នាទី ឈ្មោះ ធន ក៏បានបើកឡានចេញពីផ្ទះទៅជាមួយបងប្អូននឹងក្រុមគ្រួសាររបស់គាត់ តែខ្លួនមិនដឹងឈ្មោះ ធន បើកឡានទៅណាទេ។ ខណៈពេលនោះ ខ្លួនបានចូលទៅក្នុងផ្ទះរបស់ខ្លួនដើម្បីចូលទៅយកដែកគាស់យកទៅគាស់សំណាញ់របងលួសរបស់ឈ្មោះ ធន ដើម្បីចូលទៅក្នុងបរិវេណផ្ទះរបស់ឈ្មោះ ធន រួចហើយ រូបខ្លួនបានក្រឡេកមើលជុំវិញផ្ទះឈ្មោះ ធន អត់ឃើញមានមនុស្ស រួចហើយខ្លួនក៏បានយកដែកគាស់មកគាស់ចម្រឹងបង្អួចផ្ទះឈ្មោះ ធន ចេញ ទាំងអស់ រួចក៏បានចូលទៅតាមបង្អួចនោះទៅ ហើយរូបខ្លួនបានចូលទៅរើនៅក្នុងទូរដាក់ខោអាវ យកខោអាវចេញមកក្រៅទាំងអស់ មិនមានលុយនឹងគ្រឿងអង្កាលទេ រួចក៏បានឃើញកូនជ្រូកដាក់លុយនៅក្នុងទូហើយខ្លួនក៏បានយកទៅបោកអោយបែកបានលុយចំនួន ១.០០០.០០០ (មួយលានរៀល) មានលុយខ្មែរ និងលុយដុល្លារផង ពេលធ្វើសកម្មភាពរួចហើយខ្លួនក៏បានចេញពីផ្ទះឈ្មោះ ធន មកផ្ទះរបស់ខ្លួនវិញ ហើយខ្លួនបានយកដែកគាស់ យកទៅបោះចោលនៅក្នុងទឹកទន្លេបាសាក់បាត់ទៅ។ ចំណែកលុយដែលខ្លួនបានធ្វើសកម្មភាពគាស់ផ្ទះឈ្មោះ ធន ខ្លួនបានយកទៅចាយវាយអស់ហើយ។ លុះដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង ៣០ នាទី សមត្ថកិច្ចនគរបាលប៉ុស្តិ៍ព្រែកអំបិលបាននាំខ្លួនមកប៉ុស្តិ៍ដើម្បីសាកសួរតែម្តង។

**១.២.** ឈ្មោះ [redacted] សុខណា ចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសូមបញ្ជាក់បន្ថែមថា ខ្លួនពិតជាបានកាត់របងលួស និងគាស់ចម្រឹងបង្អួចផ្ទះរបស់ជនរងគ្រោះឈ្មោះ ធន ភេទប្រុស ដែលជាអ្នកជិតខាងលួចបានលុយចំនួន ១.០០០.០០០ (មួយលានរៀល) ពិតប្រាកដមែន។ ដោយពេលធ្វើសកម្មភាពនោះ ខ្លួនទៅតែម្នាក់ឯងទេ។ ក្រោយពីលួចលុយហើយនោះ គឺខ្លួនបានយកទៅចាយវាយអស់ហើយ។ ខ្លួនធ្លាប់ធ្វើសកម្មភាពលួចទ្រព្យសម្បត្តិរបស់គេប្រហែលចំនួន ១០ លើក មកហើយ មានដូចជា មាន់ ទា ក្រវិលកំប៉ុង លុយអ្នកភូមិ ២០០ ដុល្លារ និងក្រឡប្រហុក។

**១.៣.** ឈ្មោះ [redacted] សុខណា ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ និងនៅចំពោះមុខតំណាងអយ្យការទុកជាបានការទាំងស្រុង។ ខ្លួនសូមបញ្ជាក់នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០៧ និង ៣០ នាទីព្រឹក ខ្លួនបានដើរចេញពីផ្ទះរបស់ខ្លួនចម្ងាយប្រហែល ១០០ ម៉ែត្រ ពីផ្ទះរបស់ជនរងគ្រោះហើយខ្លួនបានកាត់របងលួស និងគាស់ចម្រឹងបង្អួចផ្ទះរបស់ជនរង



Scanned with CamScanner

គ្រោះឈ្មោះ ធន ដែលត្រូវជាអ្នកជិតខាង នៅពេលនោះខ្លួនបានធ្វើសកម្មភាពតែម្នាក់ឯងប៉ុណ្ណោះ ដោយលួចបានលុយចំនួន ១.០០០.០០០ (មួយលានរៀល) ដែលជនរងគ្រោះបានដាក់នៅក្នុងកូនជ្រូកដី ដែលមានលុយខ្មែរ និងលុយដុល្លារផង។ បន្ទាប់មកខ្លួនបានយកលុយនោះទៅចាយវាយអស់។ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចបានធ្វើការកោះហៅខ្លួនទៅកាន់ប៉ុស្តិ៍នគរបាលព្រែកអំបិល និងធ្វើការឃាត់ខ្លួនតែម្តង។ខ្លួនធ្លាប់បានធ្វើសកម្មភាពលួចនេះ ចំនួនប្រហែល ១០ ដងមកហើយ ដោយលួចដោយជា មាន់ ទា ក្រវិលកំប៉ុង លុយអ្នកភូមិ ២០០ ដុល្លារ និងក្រឡប្រហុក។ ខ្លួនមិនចេះប្រើប្រាស់គ្រឿងញៀននោះទេ ពេលសមត្ថកិច្ចឃាត់ខ្លួន ពុំមានដកហូតអ្វីនោះទេ។ ខ្លួនសូមស្នើសុំតុលាការបន្ធូរបន្ថយទោស។

**១.៤. ឈ្មោះ [redacted] សុខណា ហៅ នុយ** ក្នុងកិច្ចពិភាក្សាដេញដោល៖ ខ្លួនពិតជាបានយកដែកគាស់ផ្ទះរបស់ឈ្មោះ [redacted] ធន រើរបស់របរ បោកបំបែកកូនជ្រូកយកប្រាក់អស់ចំនួន ១.០០០.០០០ (មួយលាន) រៀល គោលដៅខ្លួន គឺចេញពីផ្ទះសំដៅទៅផ្ទះរបស់ជនរងគ្រោះតែម្តង។ ខ្លួនដឹងថាម្ចាស់ផ្ទះគេ ព្រឹកគឺចេញតែម្តង។ ខ្លួនស្គាល់យូរហើយ។ ម៉ោងគាស់ គឺយកដែកគាស់ប្រហែលកន្លះម៉ែត្រ ដោយយកពីផ្ទះ គាស់ដំបូង គឺគាស់របងខូចប្រហែលគួរសម ក្រោយមកគាស់បង្អួចដែក។ បង្អួចនៅចំហៀងខាងឆ្វេង គាស់ប្រហែលកន្លះម៉ែត្រល្មមចូលខ្លួនរួច។ ចូលដំបូងរើទូ មានកូនជ្រូកដែកទុកក្នុងទូក្នុងផ្ទះ។ តែខ្លួនមិនបានគាស់របស់របរផ្សេងទៀតទេ។ ខ្លួនក៏បោកកូនជ្រូក ហើយយកប្រាក់អស់ប្រហែល ០១ លានរៀល។ ខ្លួនសូមបញ្ជាក់ថា ខ្លួនមិនបានយករបស់របរ ឬបំផ្លាញរបស់របររបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ ខ្លួនក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ ខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀនទេ។ កន្លងមកខ្លួនធ្លាប់លួចរបស់របរបន្តិចបន្តួច តែ មាន់ ទា ក្រវិលកំប៉ុង លួចក្រឡប្រហុក។ ពីមុនមកខ្លួនធ្លាប់ធ្វើការរោងចក្រ។ មុនពេលឃាត់ខ្លួន ខ្លួនបេះខ្ទឹមឱ្យគេនៅផ្ទះ។ ចំពោះប្រាក់ដែលលួចបាន គឺចាញ់បោកស្រីអស់ហើយ តែខ្លួនមិនបានយកលុយឱ្យម្តាយទេ។ ពីមុនមកខ្លួនមិនធ្លាប់គាស់ផ្ទះគេទេ។ ខ្លួនរៀនត្រឹមថ្នាក់ទី១០។ ខ្លួនមានការសោកស្តាយ ចំពោះទង្វើរបស់ខ្លួនខ្លាំង។ ចំពោះជីវភាពរបស់គ្រួសាររបស់ខ្លួន គឺមិនសូវធូរធារទេ។ ពីមុនមកខ្លួន មិនធ្លាប់ផ្តល់ប្រាក់ឱ្យគ្រួសារនោះទេ។ ខ្លួនមិនធ្លាប់លួចរបស់របរធំដុំនោះទេ គ្រាន់តែលួចរបស់តិចតួចប៉ុណ្ណោះ។ ខ្លួនសន្យាថានឹងកែប្រែខ្លួន និងជួយរកប្រាក់ផ្គត់ផ្គង់ជួយឪពុកម្តាយ។

**២. ការស្តាប់ចម្លើយជនរងគ្រោះ**

**២.១. ឈ្មោះ [redacted]ធន** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០៥ ព្រឹក ខ្លួនបានចេញទៅធ្វើការនៅក្រុងភ្នំពេញដូចសព្វដង ហើយប្រពន្ធខ្លួននិងម្តាយក្មេកក៏បានចេញដំណើរទៅវត្តប្រាសាទនាងខ្មៅ នៅខេត្តតាកែវ ដោយបានបិទទ្វារផ្ទះចាក់សោរត្រឹមត្រូវ ហើយក៏មិនបានផ្ញើអ្នកជិតខាងអោយជួយមើលដែរ។ បន្ទាប់មកនៅវេលាម៉ោងជិត ០៣ រសៀល ថ្ងៃខែឆ្នាំ ដដែល ប្រពន្ធនិងម្តាយក្មេកបានវិលត្រឡប់មកដល់ផ្ទះវិញ រួចគាត់បានទូរស័ព្ទតាមឆាតប្រាប់ថាមានចោរចូលគាស់ផ្ទះ ពេលខ្លួនបានទទួលព័ត៌មានពីប្រពន្ធខ្លួនរួចហើយ ខ្លួនក៏ទូរស័ព្ទមកប្តឹងនគរបាលប៉ុស្តិ៍ព្រែកអំបិលអោយជួយអន្តរាគមន៍ និងរកមុខសញ្ញាចោរគាស់ផ្ទះរបស់ខ្លួន។ លុះមកដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០៣ និង ៣០ នាទីរសៀល ឈ្មោះ ជៃ



Scanned with CamScanner

សំអាត ជានាយប៉ុស្តិ៍ព្រែកអំបិលបានទូរស័ព្ទប្រាប់ខ្លួនថា មុខសញ្ញាគាស់ផ្ទះរបស់ខ្លួនត្រូវបានគាត់សួរនាំរួច ហើយ មុខសញ្ញានោះបានសារភាពថាពិតជាបានគាស់ផ្ទះ និងលួចទ្រព្យសម្បត្តិរបស់ខ្លួនពិតប្រាកដមែន។ ក្រោយពីបានទទួលព័ត៌មានពីសមត្ថកិច្ចរួច ខ្លួនក៏ចេញពីកន្លែងធ្វើការក្រុងភ្នំពេញ ឆ្ពោះមកប៉ុស្តិ៍ព្រែកអំបិលក៏ឃើញឈ្មោះ ម៉េង សុខណា ហៅ នុយ ជាក្មេងជិតខាងជាអ្នកដែលសមត្ថកិច្ចឃាត់ខ្លួនបាន។

**២.២.** ឈ្មោះ [redacted] **ធន** ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅចំពោះមុខសមត្ថកិច្ចស្រុកស្អាង ទុកជាត្រឹមត្រូវ និងបានបានការដដែល។ ខ្លួនសូមបញ្ជាក់ថា នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២៣ នៅវេលាម៉ោងប្រហែល ០៥ ព្រឹក ខ្លួនបានចេញទៅធ្វើការនៅក្រុងភ្នំពេញដូចសព្វមួយដង ហើយប្រពន្ធ និងម្ដាយក្មេករបស់ខ្លួនបានរៀបចំចេញដំណើរទៅវត្តប្រាសាទនាងខ្មៅ នៅខេត្តតាកែវ ដោយបានបិទទ្វារ ចាក់សោរត្រឹមត្រូវ ប៉ុន្តែមិនបានប្រាប់អ្នកជិតខាងអោយជួយមើលនោះទេ។ បន្ទាប់មកនៅវេលាម៉ោង ៣ រសៀល ថ្ងៃខែឆ្នាំដដែល ប្រពន្ធ និងម្ដាយក្មេករបស់ខ្លួនបានត្រឡប់មកផ្ទះវិញក៏បានឃើញរបស់របរក្នុងផ្ទះរប៉ាតរប៉ាយ និងបានវៃបំបែកកូនជ្រូកដីដែលមានទាំងលុយខ្មែរ និងលុយដុល្លារសរុបប្រហែលជាចំនួន ១.០០០.០០០ (មួយលាន) រៀល ហើយប្រពន្ធខ្លួនបានខលទៅប្រាប់ខ្លួន រួចខ្លួនបានទទួលព័ត៌មានបែបនេះ ក៏បានត្រឡប់មកផ្ទះវិញ ហើយក៏បានទៅប្តឹងសមត្ថកិច្ចឱ្យជួយអន្តរាគមន៍តែម្តង។

**២.៣.** ឈ្មោះ [redacted] **ធន** ក្នុងកិច្ចពិភាក្សាដេញដោល៖ នៅថ្ងៃកើតហេតុម៉ោង ០៥ គឺខ្លួនចេញពីផ្ទះទៅធ្វើការរៀងរាល់។ តែនៅថ្ងៃកើតហេតុ ប្រពន្ធ និងម្ដាយខ្លួនទៅបុណ្យគេនៅខេត្តតាកែវ។ ពេលម្ដាយ និងប្រពន្ធត្រឡប់មកផ្ទះម៉ោងប្រហែល ២ ជិត ៣ រសៀល ស្រាប់តែប្រពន្ធទាក់ទងខ្លួនប្រាប់ថាមានចោរចូលលួចលុយក្នុងផ្ទះ បែកកញ្ចក់ រើឥវ៉ាន់ពេញផ្ទះ។ លុយក្នុងកូនជ្រូកប្រហែលជាង ១ លានរៀល។ ផ្ទះរបស់ខ្លួនមានកាមេរ៉ា ហើយប្រគល់ឱ្យសមត្ថកិច្ចចុះស្រាវជ្រាវរក។ ពេលនោះ ខ្លួនក៏ប្តឹងសមត្ថកិច្ចតែម្តង។ ខ្លួនមិនទាមទារសំណងអ្វីទេ។ ជនជាប់ចោទរស់នៅក្បែរផ្ទះរបស់ខ្លួនប្រហែល ៥០ ម៉ែត្រ ហើយជនជាប់ចោទនេះ ធ្លាប់លួចលុយរបស់របរផ្សេង តែលឺថាទើបតែលួចគាស់ផ្ទះរបស់ខ្លួនលើកទី១។

**៣. ការស្តាប់ចម្លើយសាក្សី**

**៣.១.** ឈ្មោះ [redacted] **ស៊ូលី** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣វេលាម៉ោង ៧ និង ២០ នាទី ខ្លួននិងម្ដាយបានទៅបុណ្យគេនៅឯប្រាសាទនាងខ្មៅខេត្តតាកែវ ចំណែកប្តីខ្លួនគាត់ទៅធ្វើការនៅភ្នំពេញ។ លុះដល់ម៉ោងប្រហែល ២ និង ៣០ នាទីរសៀល ខ្លួននឹងម្ដាយបានត្រឡប់មកដល់ផ្ទះវិញ ពេលបើកទ្វារផ្ទះក៏ឃើញរបស់របរដូចជាទូខោអាវ មានបំបែកកញ្ចក់ពីរផ្ទាំង និងកូនជ្រូកដាក់លុយបែករប៉ាត់រប៉ាយពេញផ្ទះ ហើយឃើញគាស់ចម្រឹងបង្អួចអស់មួយកំណាត់ចោលលើពូកក្បែរមាត់បង្អួច បន្ទាប់មកខ្លួនបានដើរទៅមើលខាងក្រៅផ្ទះក៏ឃើញមានកាត់របងលួសសំណាញ់ចូល ឯទ្រព្យសម្បត្តិដែលបាត់បង់ មានលុយចំនួន ១.០០០.០០ (មួយលានរៀល) ក្រៅពីនេះពុំមានបាត់បង់អ្វីផ្សេងនោះទេ។ លុះដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៣ និង ៤០ នាទី ទើបសមត្ថកិច្ចបានប្រាប់ថា ចោរគាស់ផ្ទះនោះត្រូវឃាត់ខ្លួនហើយ។



Scanned with CamScanner

៣.២. ឈ្មោះ [redacted]ស្វលី ក្នុងកិច្ចពិភាក្សាដេញដោល៖ នៅថ្ងៃកើតហេតុ ខ្លួនចាក់សោរទ្វារជាមួយម្តាយ។ ពេលត្រឡប់មកផ្ទះឃើញកញ្ចក់បែកខ្ចាយ និងរបស់របររើរាយប៉ាយ ហើយឃើញបង្អួច ស្លាមកាត់ខ្សែលួស កូនជ្រុកបែកបាក់ កញ្ចក់ដែលបែក។ ឥវ៉ាន់ភាគច្រើនរើរាយប៉ាយពេញទាំងផ្ទះតែម្តង។ ពេលនោះ ខ្លួនក៏ទាក់ទងទៅប្តីរបស់ខ្លួន ដើម្បីប្រាប់ប៉ូលីស ហើយសមត្ថកិច្ចក៏ថតរាយការណ៍បន្ត តែខ្លួនមិនបានរើឥវ៉ាន់នោះទេ។

**សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធន៖**

២. ជនជាប់ចោទឈ្មោះ [redacted]**សុខណា ហៅ នុយ៖** សុំបន្ធូរបន្ថយទោស។

**ខ. សេចក្តីសន្និដ្ឋាន៖**

**១. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖**

ក្រោយពីបានស្តាប់ការសាកសួរដេញដោល និងស្តាប់ចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី មានភាពស៊ីសង្វាក់គ្នា ហើយតាមចម្លើយសារភាពដែលអាចកំណត់បានថា កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២៣ ពិតជាមានករណី លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តដោយឈ្មោះ [redacted] សុខណា ប្រព្រឹត្តនៅភូមិព្រែកតាឡៅ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល។

**២. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

ក្រោយពីបានស្តាប់ដេញដោល ឃើញថាចម្លើយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ឃើញថា កូនក្តីខ្លួនសារភាពរួចរាល់ ហើយការលួចកន្លងមកគឺរបស់របរតិចតួច ហើយចំពោះអង្គហេតុក្នុងរឿងក្តីនេះ គឺ កូនក្តីខ្លួនទើបតែគាស់ផ្ទះលើកដំបូង ស៊ីសង្វាក់ទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហេតុនេះស្នើសុំប្រធានក្រុមប្រឹក្សាបន្ធូរបន្ថយដល់កូនក្តី។

- ***ក្រោយពីបាន ស្តាប់កិច្ចពិភាក្សាដេញដោលរួចហើយ***
- ***ក្រោយពីបាន ស្តាប់សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល***

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តី**

សាលាដំបូងខេត្តកណ្តាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **៣៧២ អ.ក** ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] **សុខណា ហៅ នុយ** ភេទប្រុស អាយុ ២៤ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិព្រែកតាឡៅ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ។

**ខ. អំពីដែនកំណត់នៃការប្តឹងចំពោះអង្គហេតុ និងបុគ្គល**



Scanned with CamScanner

ផែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **សុខណា ហៅ នុយ** ៕

**គ. អំពី ពិរុទ្ធភាព**

១. តាមចម្លើយជនជាប់ចោទ តាមចម្លើយជនរងគ្រោះ និងតាមចម្លើយសាក្សី នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ នៅតំណាងអយ្យការ នៅចំពោះមុខចៅក្រមស៊ើបសួរ និងនៅក្នុងកិច្ចពិភាក្សាដេញដោលព្រមទាំងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងភស្តុតាងឯកសារផ្សេងៗ បានបង្ហាញថា អង្គហេតុដែលប្តឹងមកតុលាការ គឺជាអង្គហេតុពិតប្រាកដ ដែលបានកើតឡើង។ តុលាការយល់ឃើញថា ដោយសារតែអង្គហេតុដែលប្តឹងមកតុលាការនេះ កើតមានឡើង ដែលជាហេតុនាំឱ្យតុលាការទទួលស្គាល់នូវការកើតនូវអង្គហេតុខាងលើនេះ តុលាការនឹងបន្តពិនិត្យលើបទចោទប្រកាន់ និងអង្គហេតុ តាមរយៈការវាយតម្លៃ និងផ្ទៀងផ្ទាត់ ថាតើអង្គហេតុដែលប្តឹងមកតុលាការនោះ គឺជាបទល្មើសព្រហ្មទណ្ឌដែរឬទេ។

២. តាមសំអាងហេតុចំណុចទី១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខណា** បានបំពេញធាតុសត្យានុម័តនៃបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ជនជាប់ចោទបានសារភាពថា ជនជាប់ចោទពិតជាបានយកដែកគាស់ផ្ទះរបស់ឈ្មោះ [redacted] ធន រើរបស់របរបោកបំបែកកូនជ្រូកយកប្រាក់អស់ចំនួន ១.០០០.០០០ (មួយលាន) រៀល ដោយយកដែកគាស់ប្រហែលកន្លះម៉ែត្រ ដោយយកពីផ្ទះគាត់ដំបូង គឺគាស់របងខូចប្រហែលគួរសម ក្រោយមកគាស់បង្អួចដែក បង្អួចនៅចំហៀងខាងឆ្វេង គាស់ប្រហែលកន្លះម៉ែត្រល្មមចូលខ្លួនរួច។ ជនជាប់ចោទចូលដំបូងរើទូមានកូនជ្រូកដែកទុកក្នុងទូក្នុងផ្ទះ ហើយបានបោកកូនជ្រូក ហើយយកប្រាក់អស់ប្រហែល ១.០០០.០០០ (មួយលាន) រៀល។

៣. តាមសំអាងហេតុចំណុចទី១ ដល់ទី២ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខណា** បានបំពេញធាតុអត្តនោម័តនៃបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ជនជាប់ចោទ មានចេតនាទុច្ចរិតក្នុងការគាស់ផ្ទះរបស់ជនរងគ្រោះ ដើម្បីចូលលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ព្រោះជនជាប់ចោទបានដឹង នូវអំពើរបស់ខ្លួនថាជាបទល្មើស និងអាចព្យាករណ៍បាននូវអំពើរបស់ខ្លួន។



Scanned with CamScanner

៤. តាមសំអាងហេតុចំណុចទី១ និងទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខណា** បានបំពេញធាតុផ្សំនៃបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ៕

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត តាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើ បង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **សុខណា** បានបំពេញធាតុផ្សំនៃបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សុខណា** មានពិរុទ្ធភាពពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ៕

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ តុលាការនឹងសម្រេចប្រកាសមូលទោសក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារ តាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដោយសម្រេចប្រកាសទោស



Scanned with CamScanner

ដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] សុខណា ហៅ នុយ កើតឆ្នាំ១៩៩៩ (អាយុ ២៤ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៣ (បី) ឆ្នាំ ៦ ខែ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២៣ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ព្រោះបើពិចារណាទៅលើកាលៈទេសៈនៃបទល្មើសឃើញថា សកម្មភាពរបស់ជនជាប់ចោទបានបណ្ដាលឱ្យការបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះអស់ជាច្រើន និងបណ្ដាលឱ្យមានការភ័យខ្លាចក្នុងការរស់នៅរបស់ជនរងគ្រោះផ្ទាល់ និងជនផ្សេងទៀតដែលជាជនរងគ្រោះដោយប្រយោលពីសកម្មភាពរបស់ជនជាប់ចោទ។ ដោយឡែក កាលៈទេសៈនៃបទល្មើសនេះ ក៏បានបណ្ដាលឱ្យមានការប៉ះពាល់ដល់សុខសុវត្ថិភាពរបស់សង្គមជាតិផងដែរ។ បើពិចារណាទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទឃើញថា ជនជាប់ចោទជាមនុស្សដែលមានកម្រិតយល់ដឹងទាប។ បើពិចារណាទៅលើសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក ឃើញថា ជនជាប់ចោទពុំមានប្រភពចំណូលដើម្បីចិញ្ចឹមជីវិតនោះទេ។ បើពិចារណាទៅលើមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទឃើញថា ជនជាប់ចោទបានសារភាពចំពោះអំពើរបស់ខ្លួន ដោយបានឆ្លើយសារភាពចំពោះសកម្មភាពនៃការប្រព្រឹត្តតាំងពីដំបូង។ ហេតុនេះ តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ តុលាការយល់ឃើញថា ទណ្ឌកម្មខាងលើនេះ មានភាពធួនល្មមចំពោះជនជាប់ចោទហើយ ហើយទណ្ឌកម្មនេះនឹងអាចឱ្យជនជាប់ចោទអាចកែប្រែខ្លួនឱ្យក្លាយជាមនុស្សល្អឡើងវិញបាន ព្រោះទណ្ឌកម្មព្រហ្មទណ្ឌ មានគោលដៅទប់ស្កាត់ ព្រមានបង្ក្រាប និងអប់រំកែប្រែ ពោលគឺពុំមែនជាការសងសឹកចំពោះអំពើរបស់ជនជាប់ចោទនោះទេ។

**ឃ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។

**ជ. អំពី បណ្ដឹងរដ្ឋប្បវេណី**

តាមភស្តុតាងក្នុងសំណុំរឿងបង្ហាញថា ពុំមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ តុលាការនឹងមិនសម្រេចអំពី បណ្ដឹងរដ្ឋប្បវេណីនោះទេ។

**សេចក្ដីសម្រេច**

ក. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **សុខណា ហៅ នុយ** ភេទប្រុស កើតឆ្នាំ១៩៩៩ (អាយុ ២៤ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២៣ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ខ. ផ្ដន្ទាទោសជាទោសដាក់ពន្ធនាគារ លើជនជាប់ចោទឈ្មោះ [redacted] **សុខណា ហៅ នុយ** ភេទប្រុស កើតឆ្នាំ១៩៩៩ (អាយុ ២៤ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ៣ (បី ) ឆ្នាំ ៦ ខែ ពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្ត

កណ្តាល កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

*សំណុំរឿងព្រហ្មទណ្ឌនេះ ត្រូវបានជំនុំជម្រះជាសាធារណៈនៅចំពោះមុខជនជាប់ចោទ។*

*សាលក្រមព្រហ្មទណ្ឌនេះប្រកាសជាសាធារណៈនៅថ្ងៃ ពុធ ៥ រោច ខែភទ្របទ ឆ្នាំថោះ ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង ០០ នាទីព្រឹក នៅសាលសវនាការលេខ ១។*

*ភាគីដែលមានបំណងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើតាមការកំណត់របស់ច្បាប់។*

**ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

**ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ៥ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ខេត្តកណ្តាល, ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជីសវនាការ**

[redacted]

[redacted]



Scanned with CamScanner